ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ៣១៦ ប្រក.កសក.

# ប្រកាស

## ស្តីពី

## នីតិវិធីសម្រាប់ការទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើ ប្រចាំឆ្នាំនៅក្នុងដែនព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ



ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

## សម្រេច

**ប្រការ ១ :** ប្រកាសនេះ កំណត់នូវនីតិវិធីសម្រាប់ការទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើចំពោះព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន តាមរយៈការដេញថ្លៃជាសាធារណៈសម្រាប់ធ្វើការប្រមូលផលប្រចាំឆ្នាំ ដើម្បីផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុកជាចម្បង ឬ អាចនាំចេញបានស្របតាមមាត្រា ២០ នៃច្បាប់ស្តីពីព្រៃឈើ ។

ប្រកាសនេះអនុវត្តដូចគ្នាចំពោះនីតិវិធីសម្រាប់ការទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើលើចំការព្រៃដាំរបស់រដ្ឋ ។

**ប្រការ ២ :** រាល់ព្រៃគុបប្រចាំឆ្នាំនៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ដែលត្រូវប្រកាសដាក់ឱ្យដេញថ្លៃជាសាធារណៈ ត្រូវមានគំរោងបែបបទបច្ចេកទេសប្រមូលផល អនុផលព្រៃឈើកំណត់ក្នុងផែនការគ្រប់គ្រងព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ដែលត្រូវរៀបចំដោយផ្នែករដ្ឋបាលព្រៃឈើ និង សម្រេចដោយប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៣ :** រដ្ឋបាលព្រៃឈើ ត្រូវធ្វើសេចក្តីជូនដំណឹងជាសាធារណៈ ដោយបិទផ្សាយនៅថ្នាក់កណ្តាល អធិការដ្ឋាន ខ័ណ្ឌ ផ្នែករដ្ឋបាលព្រៃឈើ និង សាលាខេត្ត ក្រុងសាមី ឬ ផ្សព្វផ្សាយតាម បណ្តាញព័ត៌មានផ្សេងៗក្នុងរយៈពេលយ៉ាងតិចដប់ប្រាំ(១៥) ថ្ងៃ មុនថ្ងៃកំណត់បើកការដេញថ្លៃ ដោយត្រូវបញ្ជាក់ជាអាទិ៍នូវ :

- ឈ្មោះ និង ទីតាំងព្រៃគុបដែលត្រូវដេញថ្លៃ
- បរិមាណផល អនុផលព្រៃឈើ ដែលត្រូវអនុញ្ញាតឱ្យប្រមូលក្នុងព្រៃគុបនីមួយៗ
- ថ្លៃសួយសារមូលដ្ឋាននៃផល អនុផលព្រៃឈើដែលកំណត់សម្រាប់ដាក់ឱ្យដេញថ្លៃ
- ប្រាក់ធានាបណ្តោះអាសន្នសម្រាប់ការចូលដេញថ្លៃ
- ទីកន្លែង និង ពេលវេលាដែលត្រូវដេញថ្លៃ ។

**ប្រការ ៤ :** ការដេញថ្លៃត្រូវប្រព្រឹត្តទៅនៅស្នាក់ការខ័ណ្ឌរដ្ឋបាលព្រៃឈើសាមី ហើយត្រូវស្ថិតនៅក្រោមការចាត់ចែងរបស់ **គណៈកម្មការដេញថ្លៃ**ព្រៃគុបប្រចាំឆ្នាំ នៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ដែលមានសមាសភាព ដូចខាងក្រោម :

| | |
|---|---|
| ១- ប្រធានរដ្ឋបាលព្រៃឈើ ឬ តំណាង | ជាប្រធាន |
| ២- អភិបាលខេត្ត ក្រុង ឬ តំណាង | ជាអនុប្រធាន |
| ៣- នាយអធិការដ្ឋានរដ្ឋបាលព្រៃឈើ | ជាអនុប្រធាន |
| ៤- ប្រធានរតនាគារខេត្ត ក្រុង ឬ តំណាង | ជាសមាជិក |
| ៥- ប្រធានមន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុខេត្ត ក្រុង ឬ តំណាង | ជាសមាជិក |

៦- នាយខ័ណ្ឌរដ្ឋបាលព្រៃឈើ ជាសមាជិករាយការណ៍

៧- នាយផ្នែករដ្ឋបាលព្រៃឈើ ជាលេខាកត់ត្រា

**ប្រការ ៥ :** រូបវន្តបុគ្គល ឬ នីតិបុគ្គល សញ្ជាតិខ្មែរ ដែលមានសមត្ថភាពផ្នែកហិរញ្ញវត្ថុ និង វិជ្ជាជីវៈជំនាញសម្រាប់ដំណើរការប្រមូលផល អនុផលព្រៃឈើ មានសិទ្ធិចូលដេញថ្លៃព្រៃគុបនៅតាមខេត្ត ក្រុង ណាក៏បានលើកលែងតែមន្ត្រីរាជការ ។ អ្នកចូលដេញថ្លៃព្រៃគុបប្រចាំឆ្នាំនៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានត្រូវដាក់ពាក្យសុំដេញថ្លៃទៅគណៈកម្មការដេញថ្លៃព្រៃគុបឱ្យបានមុនរយៈពេលប្រាំពីរ (៧) ថ្ងៃ នៃថ្ងៃកំណត់បើកការដេញថ្លៃ ។

សំណុំលិខិតដាក់សុំដេញថ្លៃមាន ដូចខាងក្រោម :

១- ពាក្យសុំចូលដេញថ្លៃ ដែលត្រូវមានបិទតែមប្រ៊ី ។

២- អត្តសញ្ញាណប័ណ្ណថតចម្លង និង ប្រវត្តិរូបសង្ខេប ដែលបានបញ្ជាក់ទទួលស្គាល់ដោយអាជ្ញាធរ ឃុំ/សង្កាត់ ។

៣- លិខិតបញ្ជាក់អំពីមធ្យោបាយ សម្ភារៈបំរើការប្រមូលផល អនុផលព្រៃឈើ ស្ថានភាពធនធានហិរញ្ញវត្ថុ មុខរបរ វិជ្ជាជីវៈជំនាញព្រៃឈើរបស់បុគ្គល ឬ ក្រុមប្រតិបត្តិការរបស់ខ្លួន ។

៤- បង្កាន់ដៃបង់ប្រាក់ធានាបណ្តោះអាសន្ន ចំនួនដប់ (១០) ភាគរយ នៃថ្លៃសួយសារផល អនុផលព្រៃឈើសរុប ដែលរដ្ឋបាលព្រៃឈើបានកំណត់ជាមូលដ្ឋានសម្រាប់ដាក់ដេញ ថ្លៃ ។

៥- កិច្ចសន្យាបង់ប្រាក់ធានាស្ថាពរ ចំនួន ដប់ (១០) ភាគរយ នៃថ្លៃសួយសារផល អនុផលព្រៃឈើដែលដេញបានក្នុងរយៈពេលដប់ (១០) ថ្ងៃ ក្រោយពេលដេញថ្លៃបាន ។

៦- កិច្ចសន្យាសុខចិត្តប្រគល់ជូនរដ្ឋនូវប្រាក់ធានាបណ្តោះអាសន្នទាំងអស់ ក្នុងករណីដែលដេញថ្លៃបាន តែមិនព្រមចុះហត្ថលេខា ឬ ផ្តិតមេដៃលើកំណត់ហេតុដេញថ្លៃក្នុងរយៈពេលដប់ (១០) ថ្ងៃ ក្រោយពេលដេញថ្លៃបាន និង មិនបានបង់ប្រាក់ធានាស្ថាពរឱ្យបានគ្រប់ចំនួនក្នុងរយៈពេលដប់ (១០) ថ្ងៃក្រោយពេលដេញថ្លៃបាន ។

៧- លិខិតរបស់រដ្ឋបាលព្រៃឈើចំពោះបេក្ខជនដេញថ្លៃបញ្ជាក់ថា ក្នុងរយៈពេលពីរ (២) ឆ្នាំកន្លងមក បេក្ខជនមិនធ្លាប់បានប្រព្រឹត្តខុសក្នុងការដេញថ្លៃព្រៃគុប ឬ មិនធ្លាប់បានប្រព្រឹត្តបទល្មើសព្រៃឈើណាមួយ ។

**ប្រការ ៦ :** មិនអនុញ្ញាតឱ្យចូលដេញថ្លៃព្រៃគុបប្រចាំឆ្នាំ នៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានក្នុងរយៈពេលពីរ (២) ឆ្នាំ ចំពោះជនណាដែល :

- ធ្លាប់ដេញបានហើយ តែមិនគោរពបែបបទបច្ចេកទេស និង កិច្ចសន្យា
- ធ្លាប់បានប្រព្រឹត្តបទល្មើសព្រៃឈើមានលក្ខណៈធ្ងន់ធ្ងរ ឬ មិនរាងចាល ។



ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

**ប្រការ ៧ :** វិធីដេញថ្លៃព្រៃគុបប្រចាំឆ្នាំនៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ត្រូវអនុវត្តដូចខាងក្រោម :

១- នៅពេលប្រកាសបើកពិធីដេញថ្លៃ គណៈកម្មការដេញថ្លៃត្រូវពិនិត្យ និង វាយតម្លៃលើរាល់សំណុំលិខិតរបស់បុគ្គលដែលដាក់ពាក្យសុំចូលដេញថ្លៃ ហើយប្រកាសឈ្មោះបេក្ខជនដែលត្រូវមានសិទ្ធិចូលដេញថ្លៃ ។

២- គណៈកម្មការ ត្រូវប្រកាសឈ្មោះ ទីតាំងព្រៃគុប បរិមាណផលអនុផលព្រៃឈើត្រូវធ្វើការប្រមូលក្នុងព្រៃគុប និង ថ្លៃសួយសារលើផល អនុផលព្រៃឈើដែលដាក់ជាមូលដ្ឋានសម្រាប់ដេញថ្លៃ ។

៣- ការដេញថ្លៃដំបូង ត្រូវធ្វើឡើងដោយផ្ទាល់មាត់ ដោយត្រូវដេញថ្លៃឡើងដែលមានទឹកប្រាក់ជាខ្ទង់ពាន់រៀលក្នុងមួយលើក១បន្ថែមលើថ្លៃសួយសារមូលដ្ឋាន ដែលបានកំណត់សម្រាប់ដាក់ឱ្យដេញថ្លៃ ។

៤- ក្នុងករណីការដេញថ្លៃដំបូង ពុំមានបុគ្គលណាឱ្យថ្លៃឡើងលើសថ្លៃសួយសារមូលដ្ឋានទេ ការដេញថ្លៃត្រូវអនុវត្តបន្តជាសម្ងាត់ ដោយបេក្ខជននីមួយៗត្រូវសរសេរថ្លៃដេញផល អនុផលព្រៃឈើដាក់ក្នុងស្រោមសំបុត្របិតជិតជូនគណៈកម្មការដេញថ្លៃ ដោយថ្លៃដេញសម្ងាត់នេះត្រូវខ្ពស់ជាងថ្លៃសួយសារមូលដ្ឋានដែលបានកំណត់ ។ ក្នុងករណីមានបេក្ខជនច្រើនផ្តល់ថ្លៃដេញសម្ងាត់ស្មើគ្នា គណៈកម្មការដេញថ្លៃ ត្រូវអនុវត្តបន្តការដេញថ្លៃជុំរុះតាមវិធានសម្ងាត់ដដែល រហូតដល់ទទួលបានថ្លៃដេញខ្ពស់ជាងគេតែមួយ ។ បុគ្គលដែលបានឱ្យថ្លៃខ្ពស់ជាងគេចុងក្រោយនោះ គឺជាបុគ្គលទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើលើព្រៃគុបប្រចាំឆ្នាំ នៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានដែលត្រូវបានប្រកាសជាបណ្តោះអាសន្នដោយគណៈកម្មការដេញថ្លៃ ។

**ប្រការ ៨ :** ក្នុងករណីបេក្ខជនដេញថ្លៃ ពុំបានទទួលជោគជ័យក្នុងការដេញថ្លៃព្រៃគុបប្រចាំឆ្នាំនៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានណាមួយ បុគ្គលនោះមានសិទ្ធិដាក់ពាក្យចូលដេញថ្លៃព្រៃគុបនៅទីកន្លែងផ្សេងទៀតបាន ឱ្យតែសាមីជនបានបំពេញបែបបទ និង អនុវត្តបានតាមលក្ខខ័ណ្ឌនៃការដេញថ្លៃ ។

**ប្រការ ៩ :** រូបវ័ន្តបុគ្គល ឬ នីតិបុគ្គលទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើ ត្រូវបង់ប្រាក់ធានាស្ថាពរបន្ថែមដោយគិតរួមទាំងប្រាក់ធានាបណ្តោះអាសន្នផងឱ្យបានគ្រប់ចំនួនដប់ភាគរយ (១០%) នៃថ្លៃសួយសារផល អនុផលព្រៃឈើ សរុបដែលដេញបានក្នុងរយៈពេលដប់ (១០) ថ្ងៃក្រោយពេលដេញថ្លៃ ។ ប្រាក់ធានាស្ថាពរនេះ សម្រាប់ធានាលើការគោរពបទបញ្ជាបច្ចេកទេសដែលបានចែងក្នុងផែនការប្រមូលផល ប្រចាំព្រៃគុប និង កិច្ចសន្យា ដែលសាមីខ្លួនបានចុះហត្ថលេខា ។ ប្រាក់ធានាស្ថាពរនេះនឹងត្រូវទូទាត់លើថ្លៃសួយសារផល អនុផលព្រៃឈើចុងក្រោយជូនម្ចាស់ព្រៃគុបវិញ នៅពេលដែលប្រធានរដ្ឋបាលព្រៃឈើបានយល់ព្រម ចុះហត្ថលេខាលើកំណត់ហេតុត្រួតពិនិត្យ វាយតម្លៃបញ្ចប់ការប្រមូលផលព្រៃគុបដែលបញ្ជាក់នូវ ការអនុវត្តន៍សមស្រប តាមផែនការប្រមូលផល បទបញ្ជាបច្ចេកទេស និង កិច្ចសន្យា ។



ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

ប្រការ ១០: សំណុំលិខិតដេញថ្លៃ និង កំណត់ហេតុនៃការដេញថ្លៃព្រៃគុបផ្តល់ផលក្រៅពីព្រៃសម្បទាននីមួយៗ ព្រមទាំងសក្ខីប័ត្របង់ប្រាក់ធានាស្ថាពរ ត្រូវបញ្ជូនទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទជាបន្ទាន់ ក្រោយពេលដេញថ្លៃ ដើម្បីពិនិត្យ និង សម្រេច ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវចេញ សេចក្តីសម្រេចប្រគល់សិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំជូនសិទ្ធិវន្តបុគ្គលដែលដេញថ្លៃបានក្នុង រយៈពេលយ៉ាងយូរបំផុតសាមសិប (៣០) ថ្ងៃ ក្រោយពេលដេញថ្លៃបាន ។

ប្រការ ១១: ប្រាក់ធានាបណ្តោះអាសន្ន ត្រូវរឹបអូសជាស្វ័យប្រវត្តិ ក្នុងករណីដែលបុគ្គលណាដេញថ្លៃបាន ហើយមិនព្រមចុះហត្ថលេខា ឬ ផ្តិតមេដៃទទួលស្គាល់លើកំណត់ហេតុដេញថ្លៃ ឬ មិនបានបង់ប្រាក់ធានា ស្ថាពរឱ្យបានគ្រប់ចំនួនក្នុងរយៈពេលដប់ (១០) ថ្ងៃ ក្រោយពេលដេញថ្លៃបាន ។

ប្រការ ១២: ប្រាក់ធានាបណ្តោះអាសន្នរបស់បុគ្គលដែលដេញថ្លៃពុំបាន ត្រូវប្រគល់ជូនសាមីខ្លួនវិញនៅពេល ដែលជននោះបង្ហាញសក្ខីប័ត្របង់ប្រាក់កក់ធានាបណ្តោះអាសន្ន និង កំណត់ហេតុដេញថ្លៃ បញ្ជាក់ថាបុគ្គល នោះពិតជាដេញថ្លៃពុំបានមែន ។

ប្រការ ១៣: ត្រូវទុកជាមោឃៈគ្រប់ការដេញថ្លៃ ក្នុងករណីដូចខាងក្រោម :

១- ការដេញថ្លៃព្រៃគុបដោយមិនបានធ្វើសេចក្តីជូនដំណឹងដូចមានចែងក្នុងប្រការ ៣ នៃ ប្រកាសនេះ ឬ ការដេញថ្លៃខុសពីខ្លឹមសារនៃសេចក្តីជូនដំណឹង ។

២- មានភស្តុតាងបញ្ជាក់ថា បុគ្គលដេញថ្លៃបាននោះមានកលល្បិចធ្វើឱ្យការដេញថ្លៃនោះទទួល ថ្លៃសួយសារទាប ។

៣- បុគ្គលដែលដេញថ្លៃបាន មិនបានបង់ប្រាក់ធានាស្ថាពរឱ្យបានគ្រប់ចំនួនក្រោយពេលដេញថ្លៃ បានក្នុងរយៈពេលដប់ (១០) ថ្ងៃ ។

ប្រការ ១៤: ផ្អែកតាមកំណត់ហេតុដេញថ្លៃរបស់គណៈកម្មការដេញថ្លៃ ក្នុងករណីពុំមានអ្នកចូលដេញថ្លៃ ឬ ពុំមានបុគ្គលណាហ៊ានឱ្យថ្លៃលើសពីថ្លៃសួយសារមូលដ្ឋានដែលបានកំណត់សម្រាប់ដាក់ឱ្យដេញថ្លៃ ឬ ការ ដេញថ្លៃត្រូវបានចាត់ទុកជាមោឃៈដោយមូលហេតុដូចមានចែងក្នុងប្រការ ១៣ នៃប្រកាសនេះ ប្រធាន រដ្ឋបាលព្រៃឈើ អាចស្នើសុំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីផ្តល់សិទ្ធិប្រមូលផល អនុផល ព្រៃឈើក្នុងព្រៃគុបនោះតាមតម្លៃព្រមព្រៀង ។

លើកលែងតែបុគ្គលធ្លាប់បានប្រព្រឹត្តខុសដូចមានចែងក្នុងចំណុចទី ២ ឬ ចំណុចទី៣ នៃប្រការ ១៣ និង ប្រការ ៦ នៃប្រកាសនេះ រូបវន្តបុគ្គល ឬ នីតិបុគ្គលទាំងឡាយ អាចដាក់ពាក្យស្នើសុំសិទ្ធិប្រមូលផល អនុផលព្រៃឈើក្នុង ព្រៃគុបខាងលើ ស្របតាមលក្ខខណ្ឌកំណត់ក្នុងប្រការ ៥ នៃប្រកាសនេះ តាមរយៈតម្លៃព្រមព្រៀង នៅរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ។

**ប្រការ ១៥:** បុគ្គលដែលបានទទួលសិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំនៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានស្របតាមប្រកាសនេះ មិនអនុញ្ញាតឱ្យប្រគល់ ផ្ទេរ ឬ ជួលបន្តនូវសិទ្ធិប្រមូលផលនេះឱ្យតតិយជនបានឡើយ លើកលែងតែមានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ដោយសិទ្ធិវន្តបុគ្គលនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាដរាបលើរាល់សកម្មភាពអនុវត្តការប្រមូលផល អនុផលព្រៃឈើរបស់បុគ្គលទទួលសិទ្ធិបន្តនោះ ។

**ប្រការ ១៦:** ក្រោយពេលទទួលបានសេចក្តីសម្រេចប្រគល់សិទ្ធិប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំលើព្រៃគុបនៃព្រៃផ្តល់ផលក្រៅពីព្រៃសម្បទានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សិទ្ធិវន្តបុគ្គលត្រូវបំពេញបែបបទនៅរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល ដើម្បីទទួលយក **លិខិតអនុញ្ញាតប្រមូលផល អនុផលព្រៃឈើ** មុនពេលបើកការដ្ឋានដំណើរការប្រមូលផលនៅក្នុងព្រៃគុប ។

**ប្រការ ១៧:** ក្រៅពីថ្លៃសួយសារលើផល អនុផលព្រៃឈើដែលដេញថ្លៃបាន ឬ ថ្លៃសួយសារតាមតម្លៃព្រមព្រៀង សិទ្ធិវន្តបុគ្គលដែលទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើលើព្រៃគុបប្រចាំឆ្នាំ ត្រូវទទួលបន្ទុកបង់ថ្លៃបុព្វលាភបន្ថែមលើបរិមាណផល អនុផលព្រៃឈើដែលប្រមូលបានជាក់ស្តែងស្របតាមមាត្រា ៥២ នៃច្បាប់ស្តីពីព្រៃឈើ ។

**ប្រការ ១៨:** បុគ្គលទទួលបានសិទ្ធិប្រមូលផល អនុផលព្រៃឈើលើព្រៃគុបប្រចាំឆ្នាំស្របតាមប្រកាសនេះ មិនអាចផ្ទេរ ឬ លក់សិទ្ធិលើផល អនុផលព្រៃឈើទៅឱ្យបុគ្គលណាមួយផ្សេងទៀតបានឡើយ លុះត្រាតែខ្លួនបានបង់ថ្លៃសួយសារ និង បុព្វលាភលើផល អនុផលព្រៃឈើទាំងនោះរួច ។

**ប្រការ ១៩:** ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ២០ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និង ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ .ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

ចន្ទ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ២០
- ឯកសារ-កាលប្បវត្តិ

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)